**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

លេខ: ០៦៩.......កប/អក/អធក

## ជម្រាបជូន

## លោកឧកញ៉ា ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

**កម្មវត្ថុ ៖** របៀបគិតប្រាក់បំណាច់អតីតភាពការងារ ចំពោះកម្មករនិយោជិតពេញសិទ្ធិដែលបានបំពេញការងារចាប់ពី១ខែ ទៅ៦ខែនៃឆមាសនីមួយៗ។

**យោង ៖**
- មាត្រា៨៩ ថ្មី នៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ ៤៤៣ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ
- សេចក្តីណែនាំលេខ ០៥៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថានវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង
- សេចក្តីណែនាំលេខ ០៥៨ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាយកដ្ឋានអធិការកិច្ចការងារសូមជម្រាបជូនសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ជ្រាបថា កម្មករនិយោជិតពេញសិទ្ធិ ដែលបំពេញការងារចាប់ពី១ខែ ទៅ៦ខែ នៅក្នុងឆមាសនីមួយៗ នឹងអាចទទួលបាននូវប្រាក់បំណាច់អតីតភាពការងារចំនួន៧,៥ថ្ងៃនៅក្នុងឆមាសនីមួយៗ។

ដូចនេះ និយោជកមិនអាចផ្តល់ប្រាក់បំណាច់អតីតភាពការងារ ដោយគិតតាមសមាមាត្រទៅនឹងថិរវេលាធ្វើការរបស់កម្មករនិយោជិតនោះទេ ព្រោះកម្មករនិយោជិតពេញសិទ្ធិដែលធ្វើការបានយ៉ាងតិចចំនួន១ខែ (ឬ២១ថ្ងៃ) នឹងអាចទទួលបានប្រាក់បំណាច់អតីតភាពការងារចំនួន៧,៥ថ្ងៃក្នុង១ឆមាស ស្របតាមច្បាប់ស្តីពីការងារនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកឧកញ៉ាប្រធាន** មេត្តាជ្រាប និងអនុវត្តតាមការគួរ។

សូម **លោកឧកញ៉ាប្រធាន** ទទួលនូវសេចក្តីរាប់អានអំពីខ្ញុំ។

ថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២០

**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**អ៊ុក ចាន់ធូ**

**ចម្លងជូន៖**
- គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា
- ក្រុមប្រឹក្សាអាជ្ញាកណ្តាល
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- សមាគមស្បែកជើងកម្ពុជា

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*